# គណៈកម្មការទន្លេមេគង្គប្រកាសបើកការប្រកួតរូបថតនៅថ្នាក់តំបន់ដើម្បីលើកកម្ពស់កិច្ចសហការក្នុងការប្រើប្រាស់ទឹកទន្លេមេគង្គ

**វៀងច័ន្ទ ប្រទេសឡាវ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១៧** - ថ្ងៃនេះ គណៈកម្មការទន្លេមេគង្គ (MRC) ប្រកាសបើកការប្រកួតប្រជែងរូបថតនៅថ្នាក់តំបន់ក្រោមប្រធានបទ *"ភាពចម្រុះបែបនៃទន្លេមេគង្គ តាមរយៈខ្សែភ្នែករបស់អ្នក"* សម្រាប់ អ្នកថតរូបមិនមែនអាជីព គ្រប់វ័យ ដែលជាពលរដ្ឋ និងកំពុងរស់នៅក្នុងប្រទេស កម្ពុជា ឡាវ ថៃ និង វៀតណាម។

ការប្រកួតនេះ មានបំណងស្វែងរករូបថតប្រកបដោយគំនិតច្នៃប្រឌិត ដែលបង្ហាញពី ភាពចម្រុះបែបនៃអាងទន្លេមេគង្គ ដែលរាប់ចាប់ពីសម្រស់ធម្មជាតិនៃទន្លេនេះ រហូតដល់ការប្រើប្រាស់ទឹកតាមរូបភាពខុសៗគ្នា និងការប្រឈមនានា ដើម្បីបញ្ជាក់ពីតម្រូវការកិច្ចសហប្រតិបត្តិការឆ្លងដែន ដែលចាំបាច់សម្រាប់ការអភិវឌ្ឍអាងទន្លេ មេគង្គដោយចីរភាព។

លោក Pham Tuan Phan នាយកប្រតិបត្តិរបស់លេខាធិការដ្ឋាន MRC មានប្រសាសន៍ថា "ការប្រកួតប្រជែងនេះផ្តល់ឲ្យអ្នកថតរូបមិនមែនអាជីពមកពីប្រទេសជាសមាជិករបស់ MRC នូវឱកាសដើម្បីបង្ហាញពីធនធានធម្មជាតិរបស់ទន្លេ មេគង្គ ការប្រឈមខាងសេដ្ឋកិច្ច និងសង្គម ដោយសារតម្រូវការធនធានទឹកកាន់តែមានលក្ខណៈប្រកួតប្រជែង និងការបង្ហាញពីវិធីល្អៗដែលអាចដោះស្រាយផលប៉ះពាល់ទាំងនេះ"។

ក្រោមកិច្ចសហការជាមួយគណៈកម្មាធិការជាតិទន្លេមេគង្គ កម្ពុជា ឡាវ ថៃ និងវៀតណាម ការប្រកួតរូបថតនេះ ត្រូវបានរៀបចំឡើងជាផ្នែកមួយនៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះ (M-IWRMP) របស់ MRC ដែលសម្រួលឲ្យមានកិច្ចសហប្រតិបត្តិការឆ្លងដែន នៅថ្នាក់ជាតិ និងនៅកម្រិតអាងទន្លេ ក្នុងចំណោមប្រទេសក្នុងអាងទន្លេ មេគង្គក្រោម ជាមួយការប្រើប្រាស់នីតិវិធី និងមធ្យោបាយនានា MRC សម្រាប់ការចរចាអំពីការប្រើប្រាស់ទឹក ការចែករំលែកព័ត៌មាន និងការតាមដានលំហូរទឹកទន្លេមេគង្គ។

ដើម្បីចូលរួមការប្រកួតនេះ អ្នកថតរូបត្រូវផ្ញើរូបថតដើមយ៉ាងច្រើន ៥សន្លឹក ជាទម្រង់ឌីជីថល ដោយភ្ជាប់ជាមួយនូវពាក្យសុំចូលប្រកួតដែលបំពេញរួចតាមរយៈអ៊ីម៉ែល **mrcphotocontest@mrcmekong.org** ឲ្យបានត្រឹមថ្ងៃទី **២៤ ខែ កញ្ញា ឆ្នាំ ២០១៧** (ទិវាទន្លេអន្តរជាតិ)។ រូបថតនីមួយៗត្រូវមានព័ត៌មានសង្ខេបដែលអធិប្បាយពីរូបថតនោះ ជាភាសាអង់គ្លេស ឬ ភាសាកំណើតរបស់អ្នកថតរូប ដោយមិនលើស ១០០ពាក្យ ។

ម្ចាស់ជ័យលាភីនៃរូបថតទាំង ១២សន្លឹក នឹងបានទទួលរង្វាន់ជាសាច់ប្រាក់ចាប់ពីពី ១០០ ដុល្លា ដល់ ៥០០ ដុល្លារ មេដាយ និងលិខិតបញ្ជាក់ នៅក្នុងពិធីប្រគល់រង្វាន់ ដែលរៀបចំឡើងដោយលេខាធិការដ្ឋាន MRC នៅក្រុងវៀងច័ន្ទ ប្រទេសឡាវ នាចុងឆ្នាំ ២០១៧ នេះ។ រូបថតដែលឈ្នះនៅក្នុងការប្រកួតនេះអាចនឹងត្រូវដាក់តាំង និងបោះពុម្ព ក្នុងប្រតិទិន IWRMP ឆ្នាំ ២០១៨ របស់ MRC និងរបាយការណ៍ផ្សព្វផ្សាយដទៃទៀត៕

សេចក្តីពិស្តារអំពីការប្រកួតនេះ មាននៅក្នុង:
www.mrcmekong.org/news-events/events/mrcphotocontest2017

-ចប់-

ចំពោះព័ត៌មានបន្ថែម សូមទាក់ទងមក៖
ក្រុមមន្ត្រីទំនាក់ទំនងនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អ៊ីម៉ែល៖ mrcphotocontest@mrcmekong.org
ទូរស័ព្ទ៖+856 21 263 263